**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**
**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខ: ៧០២/១៧ ......

**ជាតិ សាសនា ព្រះមហាក្សត្រ**

30

**គោរពជូន**

**ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**តាមរយៈ:** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។
**កម្មវត្ថុ:** របាយការណ៍លទ្ធផលកិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ។
**យោង** : ស្មារតីកិច្ចប្រជុំ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។

តបតាមកម្មវត្ថុ និងយោងខាងលើ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានកិត្តិយស សូមគោរពជម្រាបជូន ឯកឧត្តម រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ មេត្តាជ្រាបថា: នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង១៤ និង៣០នាទី រសៀល នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបើកកិច្ចផ្សព្វផ្សាយគោលកាណ៍ដឹកនាំ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងឯកឧត្តម ឧត្តមសេនីយ៍ឯក **ចៅង សំអាត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ:

- សរុបចំនួនអ្នកចូលរួម ៧០ នាក់ (ប្រុស ៥៩ នាក់ ស្រី ១១នាក់ )
- អវត្តមានចំនួន ១៤ រូប (និងធ្វើការផ្សព្វផ្សាយនៅពេលក្រោយ) ក្នុងនោះ
  - បេសកកម្មចំនួន: ០៣ រូប
  - ច្បាប់ចំនួន : ០៤ រូប
  - គ្មានមូលហេតុចំនួន: ០៧ រូប

### ១-អំពីខ្លឹមសារ នៃកិច្ចប្រជុំ

ផ្សព្វផ្សាយគោលការណ៍ដឹកនាំ ស្តីពីវិធានការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ។

### ២-អំពីវិធានការ និងការប្តេជ្ញាចិត្ត ក្នុងការអនុវត្ត

ដើម្បីចូលរួមក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា កម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការទាំងអស់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ធ្វើការប្តេជ្ញាចិត្ត ដូចខាងក្រោម:

-គាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

-ជំរុញ និងបង្កើនការយកចិត្តទុកដាក់លើការងារគ្រប់គ្រងមន្ត្រីក្រោមឱវាទ តាមរយៈការអប់រំសតិអារម្មណ៍ ការលើកទឹកចិត្ត ការដោះស្រាយកង្វល់ ការថ្នាំងថ្នាក់ ភាពអសកម្មនានាក្នុងអង្គភាពឲ្យបានល្អប្រសើរ ចៀសវាងការយល់ច្រឡំ ឬ ធ្លាក់ក្នុងការញុះញង់អូសទាញរបស់ពួកប្រឆាំង ។

-ត្រៀមលក្ខណៈសម្បត្តិចូលរួមបង្ការទប់ស្កាត់ និងដោះស្រាយសភាពការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដែលអាចកើតមានឡើងជាយថាហេតុ ។

-បន្តពង្រឹងអង្គភាពឲ្យបានរឹងមាំ ដើម្បីធានាថា មន្ត្រីទាំងអស់គឺជាកម្លាំងដែលមានឆន្ទៈ និងឧត្តមគតិ ស្មោះត្រង់ការពារដាច់ខាតព្រះមហាក្សត្រ រដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលស្របច្បាប់ និងការពាររាល់សមិទ្ធិផលទាំងឡាយ។

-ប្តេជ្ញាចូលរួមទប់ស្កាត់ការញុះញង់ ដែលបង្កឲ្យមានអំពើហិង្សា ចាប់ពីពេលនេះ រហូតដល់ក្រោយពេលបោះឆ្នោត នាឆ្នាំ២០១៨ ខាងមុខ ។

-ប្រមូលផ្តុំ និងដឹកនាំកងកម្លាំង រួមចំណែកការពារ រក្សាស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងសេចក្តីត្រូវការចាំបាច់ នៃសភាពការការណ៍ដែលអាចកើតមានជាយថាហេតុ ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម**ឯកឧត្តម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

សូម**ឯកឧត្តម** មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ១០ ឆ្នាំ២០១៧

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក ថោង សំអាត

**គោរពជូន**

**ឯកឧត្តម រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

មេត្តាជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ១០ ឆ្នាំ២០១៧

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ង ង៉ុកអេង

**ចម្លងជូន:**

- *អគ្គស្នងការដ្ឋាននគរបាលជាតិ*
- *អគ្គលេខាធិការដ្ឋាន*
- *អគ្គាធិការដ្ឋាន*
- *អគ្គនាយកដ្ឋានរដ្ឋបាល*

*"ដើម្បីជូនជ្រាប"*